# ផែនការយុទ្ធសាស្ត្រជាតិបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន ឆ្នាំ២០០៨_២០១៥

## សន្និសីទជាតិលើកទី៣ស្តីពីជំងឺអេដស៍

សាលសន្និសីទចតុមុខ

១០_១២ កញ្ញា ២០០៨

សាស្ត្រាចារ្យ គុំ កាណាល់

ប្រធានមជ្ឈមណ្ឌលជាតិគាំពារមាតានិងទារក

| សូចនាករ | ចំណុច មូលដ្ឋាន | កាល បរិច្ឆេទ | ចំណុចគោលដៅ | | | |
|---|---|---|---|---|---|---|
| | | | ២០០៨ | ២០០៩ | ២០១០ | ២០១៥ |
| ១) ចំនួន (%) សេវាថែទាំផ្ទៃពោះដែលធ្វើតេស្ដឈាមរកមេរោគអេដស៍ | ៩៥/៩៥៦<br>១០% | ដំណាច់ឆ្នាំ ២០០៧ | ១៩៣<br>២០% | ២៨៩<br>៣០% | ៣៨៦<br>៤០% | ៥០០<br>៥១% |
| ២) ចំនួន (%) ស្រុកប្រតិបត្តិដែលមានសេវាបង្ការការចម្លងមេរោគអេដស៍យ៉ាងតិចមួយកន្លែង | ៥៨/៧៧<br>(៧៥%) | ដំណាច់ឆ្នាំ ២០០៧ | ៨៥% | ៩០% | ១០០% | ១០០% |
| ៣) ចំនួន (%) ស្ត្រីមានផ្ទៃពោះដែលមកទទួលសេវាថែទាំផ្ទៃពោះនៅមណ្ឌលដែលមានសេវាបង្ការការចម្លងមេរោគអេដស៍ពីម្ដាយទៅកូនបានមកធ្វើតេស្ដឈាមរកមេរោគអេដស៍ និងទទួលលទ្ធផលតេស្ដ | ៦៦,១៨៦/៩១,០២១<br>៧២.៧% | ដំណាច់ឆ្នាំ ២០០៧ | ៧៥% | ៨០% | ៨៥% | ៩៥% |
| ៤) ចំនួន (%) ស្ត្រីមានផ្ទៃពោះនៅទូទាំងប្រទេសបានធ្វើតេស្ដឈាមរកមេរោគអេដស៍ (មណ្ឌលបង្ការការចម្លងមេរោគអេដស៍ពីម្ដាយទៅកូន និងគ្លីនិកវ៉ាក់) និងទទួលលទ្ធផលតេស្ដ | ៦៦,១៨៦/៤១០,០០០<br>១៤.៩% | ដំណាច់ឆ្នាំ ២០០៧ | ២៥% | ៣៥% | ៥០% | ៧៥% |
| ៥) ចំនួន (%) ដៃគូស្ត្រីបានធ្វើតេស្ដឈាមរកមេរោគអេដស៍និងទទួលលទ្ធតេស្ដ | ១០,៦៧០/៥០,៦០៤<br>២១.១% | ដំណាច់ឆ្នាំ ២០០៧ | ២៥% | ៣០% | ៣៥% | ៤០% |

| សូចនករ | ចំណុចមូលដ្ឋាន | កាលបរិច្ឆេទ | ចំណុចគោលដៅ | | | |
|---|---|---|---|---|---|---|
| | | | ២០០៨ | ២០០៩ | ២០១០ | ២០១៥ |
| ៦) ចំនួន (%) ស្ត្រីមានផ្ទៃពោះផ្ទុកមេរោគអេដស៍ ដែលបានទទួលឱសថប្រឆាំងមេរោគអេដស៍ ដើម្បីបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន (បង្ការឬព្យាបាល) | ៥០៥/ ៤៥០៩ ១១.២% | ដំណាច់ឆ្នាំ ២០០៧ | ៣០% | ៤០% | ៥០% | ៧៥% |
| ៧) ចំនួន (%) កុមារដែលកើតពីម្តាយផ្ទុកមេរោគអេដស៍ចាប់ផ្តើមបង្ការដោយប្រើឱសថកូទ្រីម៉ុកសាសុលក្នុងកំឡុងពីខែដំបូងនៃកំណើត | គ្មាន | | ២៥% | ៣៥% | ៤៥% | ៧០% |
| ៨) ចំនួន (%) កុមារដែលកើតពីម្តាយផ្ទុកមេរោគអេដស៍បានធ្វើតេស្តឈាម (ភីស៊ីអ) រកមេរោគអេដស៍ក្នុងកំឡុងពេល ១២ខែនៃកំណើត | គ្មាន | | ២៥% | ៣៥% | ៤៥% | ៧០% |
| ៩) ចំនួន (%) កុមារដែលកើតពីម្តាយផ្ទុកមេរោគអេដស៍បានចិញ្ចឹមដោយទឹកដោះម្តាយសុទ្ធឬដោយទឹកដោះគោម្សៅសុទ្ធរយៈពេល៦ខែដំបូង | គ្មាន | | ១០០% | ១០០% | ១០០% | ១០០% |
| ១០) (%) កុមារឆ្លងមេរោគអេដស៍ពីម្តាយ | ៣១.១% | ២០០៧ | ២៧.៥% | ២៥% | ២២.៥% | ១៦.៣% |

# គោលបំណងនៃផែនការយុទ្ធសាស្ត្រជាតិបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន

- ពង្រីកសេវាបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន ដើម្បីអោយស្ត្រីមានផ្ទៃពោះ ព្រមទាំងកូនរបស់គាត់បានទទួលសេវានេះបានភាគច្រើន ជាពិសេសស្ត្រីដែលជាក្រុមប្រឈមខ្ពស់ទៅនឹងមេរោគអេដស៍
- ពង្រឹងការធ្វើផែនការកម្មវិធី ការគ្រប់គ្រង ការសំរបសំរួល ការអនុវត្តន៍ និងការអភិបាលនៅគ្រប់កំរិត
- ពង្រឹងការអនុវត្តន៍ និងតាមដានលើការអនុវត្តន៍គោលនយោបាយជាតិ និងគោលការណ៍ណែនាំជាតិស្តីពីអាហារូបត្ថម្ភ និងការចិញ្ចឹមកូនក្នុងបរិបទនៃជំងឺអេដស៍
- ពង្រឹងការប្រមូលទិន្នន័យ ការគ្រប់គ្រងទិន្នន័យ និងការប្រើប្រាស់ទិន្នន័យឱ្យមានប្រសិទ្ធិភាពនៅគ្រប់កំរិត សំរាប់ធ្វើគម្រោងផែនការ សំរាប់វាយតម្លៃលើការអនុវត្តន៍កម្មវិធីដើម្បីអោយកម្មវិធីកាន់តែមានភាពល្អប្រសើរឡើង និងសំរាប់តាមដានអ្នកជំងឺអោយបានជាប់ជាប្រចាំ

# គោលបំណងទី១៖  ពង្រីកសេវាបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន

**យុទ្ធវិធីសំខាន់ៗ:**

- បង្កើនចំនួនស្ត្រីមានផ្ទៃពោះអោយមកទទួលប្រើប្រាស់សេវាបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន ដោយធ្វើអោយគាត់យល់ពីសារៈសំខាន់នៃកម្មវិធី តាមរយៈប្រព័ន្ធផ្សព្វផ្សាយ និងតាមរយៈសាររបស់សហគមន៍
- លើកកំពស់ការអនុវត្តន៍វិធីផ្តល់ប្រឹក្សាធ្វើតេស្តឈាមដែលផ្តួចផ្តើមឡើងដោយអ្នកផ្តល់សេវា៖ គឺដើម្បីអោយស្ត្រីមានផ្ទៃពោះបានធ្វើតេស្តឈាមគ្រប់ៗគ្នា តាមរយៈការបង្កើនការប្រើប្រាស់សេវាបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន និងសេវាធ្វើតេស្តឈាមដែលមានស្រាប់
- ធានាអោយបាននូវការបង្ការជាសកល និងការបង្ការក្រោយប្រឈមទៅនឹងការឆ្លងនឹងមេរោគអេដស៍ក្រោយ ការមុតរបួសដើម្បីជួយសម្រួលដល់ការភ័យព្រួយនៃបុគ្គលិកសុខាភិបាល
- ធ្វើតេស្តឈាមដល់ស្ត្រីដែលមិនដឹងពីស្ថានភាពផ្ទុកមេរោគអេដស៍របស់ខ្លួននៅពេលឈឺពោះសំរាល នៅតាមមណ្ឌលដែលមានសេវាបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន ដើម្បីបានផ្តល់ឱសថប្រឆាំងមេរោគអេដស៍ដល់ស្ត្រីនិងកូនបានទាន់ពេលវេលា
- ពង្រឹងទំនាក់ទំនងរវាងមណ្ឌលសុខភាព សេវាធ្វើតេស្តឈាម សេវាសំរាល សេវាOI/ART សេវាថែទាំកុមារ សេវាផែនការគ្រួសារ សេវាជំងឺកាមរោគ  សេវាថែទាំអ្នកជំងឺនៅតាមផ្ទះ ដើម្បីធានាថាស្ត្រីផ្ទុកមេរោគអេដស៍ និងកុមារបានទទួលការថែទាំព្យាបាល និងតាមដានបានល្អ។

# គោលបំណងទី២៖
# ពង្រឹងការគ្រប់គ្រងកម្មវិធីបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន

**យុទ្ធវិធីសំខាន់ៗ៖**

- ពង្រឹងការធ្វើផែនការ ដោយតំរូវអោយមានផែនការសកម្មភាពប្រចាំឆ្នាំ និងគោលដៅចំណុចនៅថ្នាក់ជាតិ ថ្នាក់ខេត្ត និងថ្នាក់ស្រុកប្រតិបត្តិ
- ពង្រឹងពីតួនាទីរបស់ក្រុមការងារបច្ចេកទេស និងលេខាធិការដ្ឋាននៃកម្មវិធីបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន
- ធ្វើវិមជ្ឈការការបណ្តុះបណ្តាល និងការអភិបាលដល់ថ្នាក់ខេត្ត និងថ្នាក់ស្រុកប្រតិបត្តិ
- ពង្រឹងការសហការ និងសហប្រតិបត្តិការជាមួយមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ ព្រមទាំងជាមួយក្រសួងដទៃទៀត ជាពិសេសក្រសួងកិច្ចការនារី

# គោលបំណងទី៣៖
# ពង្រឹងការអនុវត្តន៍គោលនយោបាយនិងគោលការណ៍ណែនាំជាតិស្តីពីអាហារូបត្ថម្ភ និង ការចិញ្ចឹមកូនក្នុងបរិបទនៃជំងឺអេដស៍

**យុទ្ធវិធីសំខាន់ៗ៖**

- ពង្រឹងការអនុវត្តគោលនយោបាយនិងគោលការណែនាំជាតិស្តីពីអាហារូបត្ថម្ភ និងការចិញ្ចឹមទារកនិងកុមារតូចៗក្នុងបរិបទនៃ ជំងឺអេដស៍
- ពង្រឹងសមត្ថភាពមន្ត្រីបុគ្គលិកស្តីពីអាហារូបត្ថម្ភ និងការចិញ្ចឹមទារកនិងកុមារតូចៗ ក្នុងបរិបទនៃជំងឺអេដស៍នៅគ្រប់កំរិត

# គោលបំណងទី៤: ធ្វើអោយប្រសើរឡើងនូវប្រព័ន្ធតាមដាននិងវាយតម្លៃ និងការប្រើប្រាស់ទិន្នន័យ

**យុទ្ធវិធីសំខាន់ៗ:**

- កែសំរួលឧបករណ៍សំរាប់ប្រមូលទិន្នន័យ និងសំរាប់ធ្វើរបាយការណ៍ ដើម្បីអោយកម្មវិធីអាចប្រមូលបាននូវសូចនករសំខាន់ៗ និងធ្វើការតាមដានបានល្អប្រសើរ (ឧ: ពីសេវាថែទាំផ្ទៃពោះ ទៅសេវាសំរាល ទៅសេវាថែទាំកុមារដើម្បីធ្វើរោគវិនិច្ឆ័យ តាមដានការចិញ្ចឹមទារក និង តាមដានបន្ត ។ល ។)
- ពង្រឹងការកត់ត្រា និងធ្វើរបាយការណ៍នៅតាមកន្លែងផ្តល់សេវា
- ពង្រឹងការគ្រប់គ្រងទិន្នន័យ និងវិភាគទិន្នន័យនៅថ្នាក់ស្រុកប្រតិបត្តិ ថ្នាក់ខេត្ត និងថ្នាក់ជាតិ
- លើកទឹកចិត្តអោយមានការចែកចាយទិន្នន័យអោយគ្នាទៅវិញទៅមករវាងកម្មវិធីជំងឺអេដស៍និងកម្មវិធីសុខភាពមាតានិងទារក ទាំងនៅថ្នាក់ជាតិ ថ្នាក់ខេត្ត និងថ្នាក់ស្រុកប្រតិបត្តិ
- លើកទឹកចិត្តអោយមានការផ្តួចផ្តើមធ្វើកម្មវិធីសាកល្បង និងសិក្សាស្រាវជ្រាវប្រតិបត្តិ ដោយប្រើប្រាស់ឧបករណ៍តាមដាននិងវាយតម្លៃ និងហេដ្ឋារចនាសម្ព័ន្ធដែលមានស្រាប់ ដើម្បីធ្វើការវាយតម្លៃពីផលប៉ះពាល់នៃគំរោងទាំងនោះ





# THANK YOU